ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ចង្ហោន
# រយៈពេល ៣ឆ្នាំ (កញ្ញា ២០២៥ - សីហា ២០២៨)

ឈ្មោះសហគមន៍នេសាទ ៖ ចង្ហោន
ភូមិ ៖ ចង្ហោន
សង្កាត់ ៖ ព្រែកត្នោត
ក្រុង ៖ បូកគោ
ខេត្ត ៖ កំពត

---

រៀបចំដោយរដ្ឋបាលជលផល សហការជាមួយខណ្ឌរដ្ឋបាលជលផលកំពត(គម្រោងជលផលសមុទ្រនិងតំបន់ឆ្នេរប្រកបដោយចីរភាព)

## មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**...........................................................................១

**២- អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**.....................................................២

ក- ប្រជាពលរដ្ឋ...........................................................................២

ខ- មុខរបរ.................................................................................៣

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**.................៣

ក- ទីតាំង..................................................................................៣

ខ- ដែននេសាទ............................................................................៣

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស...........................................៣

ឃ- ធនធានជលផល........................................................................៤

**៤- ការធ្វើនេសាទ**.......................................................................៤

ក- អ្នកនេសាទ.............................................................................៤

ខ- ឧបករណ៍នេសាទ.......................................................................៤

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ......................................................៦

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**...................................................៧

**ក- ទស្សនៈវិស័យ**.........................................................................៧

**ខ- គោលបំណង**...........................................................................៧

**គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**.............................................៧

**ផ្នែកទី១.ការអភិបាលកិច្ចនិងការគ្រប់គ្រង**................................................៧

គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ...........................................៧

គ២- ផែនការប្រជុំប្រចាំខែនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ.............៨

គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល...................................................៨

គ៤- ផែនការប្រើប្រាស់ឧបករណ៍នេសាទ....................................................៩

គ៥- ផែនការទប់ស្កាត់បទល្មើសជលផល...................................................១០

គ៦- ផែនការកែលម្អកន្លែងនេសាទសហគមន៍...............................................១១

គ៧- ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ.........................១២

គ៨- ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ.......................១២

គ៩- ផែនការគ្រប់គ្រងព្រៃកោងកាង.......................................................១៣

**ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ**........................................១៤

គ១០- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ.................................១៤

គ១១- ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ....................................១៥

គ១២- ផែនការបង្កើតកន្លែងទេសចរណ៍ធម្មជាតិរបស់សហគមន៍នេសាទ.........................១៦

គ១៣- ផែនការបង្កើតក្រុមឥណទានដើម្បីបង្កើនមុខរបរ......................................១៧

ផ្នែកទី៣. **ការចូលរួមរបស់ស្ត្រីនិងយុវជន ការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ**.................១៨

គ១៤- ផែនការផ្សព្វផ្សាយនិងជ្រើសរើសស្ត្រីនិងយុវជនចូលជាសមាជិកសហគមន៍នេសាទ..........១៨

គ១៥- ផែនការកសាងភាពធននឹងការប្រែប្រួលអាកាសធាតុ..................................១៨

**ផ្នែកទី៤. ការទំនាក់ទំនងនិងគៀងគរធនធាន**........................................................១៩

គ១៦-ផែនការទំនាក់ទំនងនិងគៀងគរធនធាន........................................................១៩

គ១៧- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍........................................................២០

**ឃ- ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**........................................................២០

**ង. ផែនការយុទ្ធសាស្ត្រ**........................................................២១

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិថ្មី រយៈពេល៣ឆ្នាំ**..............................២២

**តារាងពេលវេលាការងារ**........................................................២៩

# ផែនការគ្រប់គ្រង
# តំបន់សហគមន៍នេសាទ

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទចង្ហោន ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២ និងបានបោះឆ្នោតឡើងវិញនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៥។ ហើយត្រូវបានចុះបញ្ជីជាផ្លូវការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមប្រកាសលេខ១២៣ ប្រក.កសក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១។

សហគមន៍នេសាទចង្ហោន មានទីតាំងស្ថិតនៅភូមិចង្ហោន សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត។ សមាជិកសហគមន៍នេសាទសរុបចំនួន៤១១នាក់ ស្រី១៩១នាក់ ក្នុងនោះចំនួនគ្រួសារសរុបចំនួន២០៥គ្រួសារ។ សហគមន៍នេសាទនេះ មានគណៈកម្មការចំនួន៩នាក់ ស្រី២នាក់ និងមានក្រុមល្បាតចំនួន៧នាក់។

កន្លងមកសហគមន៍នេសាទចង្ហោន បានរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ បានកំណត់ព្រំប្រទល់ផែនទីកន្លែងសហគមន៍នេសាទ ព្រមទាំងរចនាសម្ព័ន្ធគ្រប់គ្រងដែលបានបែងចែកតួនាទី និងភារកិច្ចការទទួលខុសត្រូវរបស់គណៈកម្មការ និងសមាជិកសហគន៍ដែលមានការទទួលស្គាល់ឯកភាពពីភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋាន។ ចំពោះផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ គណៈកម្មការនិងសមាជិកសហគមន៍នេសាទសហការជាមួយដៃគូពាក់ព័ន្ធ បានអនុវត្តសកម្មភាពសំខាន់ៗ រួមមាន ការចូលរួមប្រជុំនិងបិទផ្សាយផែនទីកន្លែងសហគមន៍នេសាទ រៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ បង្កើតធនាគារក្តាមសេះសាកល្បងដើម្បីបង្កើនផលស្តុកក្តាមសេះក្នុងធម្មជាតិ ផ្តួចផ្តើមសកម្មភាពមុខរបរតាមរយៈសេវាកម្មទេសចរណ៍ជលផល ចូលរួមយុទ្ធនាការផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពនានា រៀបចំក្រុមល្បាតសហគមន៍នេសាទ និងចុះល្បាតដោយសហការជាមួយសមត្ថកិច្ចជលផល អាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទកើតមានក្នុងកន្លែងសហគមន៍នេសាទ។ សកម្មភាពទាំងនេះ សបញ្ជាក់ពីការប្រឹងប្រែងអនុវត្តសកម្មភាពស្របតាមផែនការគ្រប់គ្រងរបស់ខ្លួនទៅតាមធនធានដែលមានកំណត់។ បច្ចុប្បន្នសហគមន៍នេសាទចង្ហោន កំពុងខិតខំគៀងគរការចូលរួមធនធាននិងការគាំទ្រនានាក្នុងការដោះស្រាយបញ្ហាប្រឈមដែលនៅតែកើតមានឡើងដូចខាងក្រោម៖

- ផលនេសាទថយចុះបណ្តាលពីសកម្មភាពនេសាទលើសកម្រិត ការនេសាទដោយប្រើប្រាស់ស្បៃមុង តម្រូវការកើនឡើង ការប្រើឧបករណ៍នេសាទបំផ្លិចបំផ្លាញ មានដូចជា ទូកអូសស្រទាប់បាតនៅទឹករាក់ ការប្រើប្រាស់ឧបករណ៍ឆក់ជាដើម ព្រមទាំងការប្រជែងគ្នាក្នុងការនេសាទរវាងសកម្មភាពនេសាទខ្នាតតូច នេសាទជាប្រពៃណី និងនេសាទខ្នាតធំ។ សហគមន៍នេសាទសង្កេត ឃើញថា ជះឥទ្ធិពលដល់ផលចាប់ត្រី និងវារីសត្វសមុទ្រផ្សេងៗមានការថយចុះ
- ការថយចុះប្រព័ន្ធអេកូស៊ីស្ទែមជលផលសមុទ្រ ដូចជា ជម្រកជលផលសមុទ្រ ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម ដែលកំពុងរងផលប៉ះពាល់ពីការនេសាទដែលបំផ្លិចបំផ្លាញ ការអភិវឌ្ឍមិនសមស្រប ជាដើម
- សមត្ថភាពនិងចំណេះដឹងរបស់គណៈកម្មការ និងសមាជិកនៅមានកម្រិត ដូចជា ខ្វះជំនាញបច្ចេកទេសលើការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងខ្វះការអនុវត្តការងារគ្រប់គ្រងតាមបែបសហគមន៍មូលដ្ឋាន ឬសហគ្រប់គ្រងនៅមានកម្រិត

- ការជ្រើសរើសមុខរបរមានកម្រិត និងងាយរងគ្រោះ ដោយពឹងផ្អែកលើប្រភពចំណូលតែមួយ និងផលចាប់ពីធម្មជាតិ អស្ថេរភាពតម្លៃផលិតផលកសិកម្មដែលកំណត់ដោយឈ្មួញកណ្ដាលក្នុងតំបន់ ពិបាកក្នុងការទទួលបានតម្លៃបន្ថែមលើផលផលិតផលដោយសារគុណភាពផលិតផលនិងការកែច្នៃ ខ្វះទន់ក្នុងការចាប់ផ្ដើម និងជំនាញលើមុខរបរ ដូចជាការបង្កើនសេវាទេសចរណ៍ជលផល វារីវប្បកម្មដែលមិនប្រើចំណីជាដើម
- ការប្រែប្រួលអាកាសធាតុនិងគ្រោះធម្មជាតិដែលប៉ះពាល់លើការប្រកបរបរនេសាទ សេវាទេសចរណ៍ជលផល លំនៅដ្ឋាន និងគុណភាពទឹកសមុទ្រ ដូចជា កំណើនជាតិពុលក្នុងទឹក កំដៅទឹកសមុទ្រអាចនឹងប៉ះពាល់ដល់ទេសចរណ៍ជលផល និងវារីវប្បកម្ម
- ការចោលសំរាម ផ្លាស្ទីក និងកាកសំណល់នានាដែលនាំឱ្យប៉ះពាល់ដល់គុណភាពទឹកសមុទ្រ បង្កឱ្យមានជាតិពុល និងសោភណ្ឌភាពនៅក្នុងសហគមន៍នេសាទ
- សមត្ថភាពរបស់គណៈកម្មការសហគមន៍នេសាទនៅមានកម្រិត ដូចជា ការងាររដ្ឋបាល ការអនុវត្តសកម្មភាព ការងារគ្រប់គ្រង ការងារសេដ្ឋកិច្ច ការការពារធនធានជលផល និងសកម្មភាពការងារល្បាត
- លទ្ធភាពចូលរួមអនុវត្តច្បាប់មានកម្រិត ដោយខ្វះមធ្យោបាយ ដូចជាឧករណ៍ទំនាក់ទំនងរាយការណ៍ ទូកល្បាតដែលធន នឹងអាកាសធាតុ ប្រភពថវិកាគាំទ្រសកម្មភាពល្បាត ការចូលរួមពីសមាជិកមានកម្រិត ការផ្សព្វផ្សាយច្បាប់ ស្តីពីជលផលមិនបានដិតដល់ជាប្រចាំ។

ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទចង្អោន ឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ លេខ៦៣៣ ជផ ចុះ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ត្រូវបានរៀបចំកែសម្រួលឡើងវិញ ដោយធ្វើបច្ចុប្បន្នភាពនូវទិន្នន័យសហគមន៍នេសាទ សកម្មភាពនានាស្របនឹងនិន្នាការថ្មីៗ តម្រូវការសហគមន៍ និងការប៉ាន់ប្រមាណថវិកា ដោយផ្ដោតលើការអភិរក្សជលផល ការបង្កើតមុខរបរ ការគ្រប់គ្រងសកម្មភាពនេសាទ និងការប្រើប្រាស់ធនធានជលផលនៅក្នុងសហគមន៍នេសាទប្រកបដោយនិរន្តរភាព និងការចូលរួមចំណែកកាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ស្របតាមប្រការ៣០ នៃប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំសហគមន៍នេសាទ។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

ប្រជាពលរដ្ឋសរុបក្នុងតំបន់មានចំនួន ៨៥០ នាក់ ស្រី៤៧២ នាក់ ក្នុងនោះមានចំនួន ២៥០ គ្រួសារ។ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០% ។

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរ៤៣នាក់ ស្រី២៥នាក់ កម្រិត ថ្នាក់បឋមសិក្សាចំនួន២៨៩នាក់ ស្រី១៤៣នាក់ កម្រិតវិទ្យាល័យចំនួន៧៩នាក់ ស្រីចំនួន២៣នាក់ និងកម្រិតឧត្តមសិក្សាគ្មាន ។

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន២៧នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន៧នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន១១នាក់ ស្រី៣នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន២៧នាក់ ស្រី១៦នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន១៥នាក់ ស្រី៧នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន៥នាក់ ស្រី២នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទ ចំនួន ១៨០ គ្រួសារ
- ធ្វើស្រែ ចំនួន ១០ គ្រួសារ ទំហំ៧៥ ហិកតា
- ដាំបន្លែ ចំនួន ៨ គ្រួសារ
- ចិញ្ចឹមសត្វ ចំនួន១០គ្រួសារ
- ធ្វើវារីវប្បកម្ម ចំនួន ១២ គ្រួសារ
- ជាងផ្ទះ ចំនួន ១៥ គ្រួសារ
- លក់ដូរ ចំនួន ២០ គ្រួសារ
- កម្មករ ចំនួន១៥០ គ្រួសារ
- កែច្នៃផលនេសាទ ចំនួន១០ គ្រួសារ (បង្គាក្រៀម និងត្រីចំហុយ)។

ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំមានចំនួន ៧ ៥៦០ ០០០ រៀល ។

## ៣ កន្លែងសហគមន៍នេសាទ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក. ទីតាំង**

កន្លែងសហគមន៍នេសាទចង្ហោន ជាដែននេសាទសមុទ្រ មានកន្លែងនេសាទតាមឆ្នេរ កន្លែងអភិរក្សជលផល ស្មៅសមុទ្រ នាទីព្រៃកោងកាង វាលភក់ ព្រែក ដែលជាដែននេសាទសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងភូមិចង្ហោន សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត។ សហគមន៍នេសាទចង្ហោន មានទំហំ **១ ៣៣៨** ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅ ក្នុងកិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទ។

សហគមន៍នេសាទចង្ហោន មានព្រំប្រទល់ ៖

- ខាងជើងជាប់នឹងសង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត
- ខាងត្បូងជាប់នឹងលំហសមុទ្រ សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត
- ខាងកើតជាប់នឹងព្រែកក្ដាត សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត
- ខាងលិចជាប់នឹងកន្លែងសហគមន៍នេសាទព្រែកត្នោត សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត។

**ខ. ដែននេសាទ**

កន្លែងសហគមន៍នេសាទចង្ហោន មានលំហសមុទ្រ វាលភក់ នាទីព្រៃកោងកាង ស្មៅសមុទ្រ និងព្រែក ចំនួន៣ គឺ៖

| | | |
|---|---|---|
| -លំហសមុទ្រ | ទំហំ ១ ៣២៧,២ ហិកតា | នេសាទពេញមួយឆ្នាំ ក្នុងនោះ |
| . វាលភក់ | ទំហំ ២០,៨ ហិកតា | នេសាទពេញមួយឆ្នាំ |
| . ស្មៅសមុទ្រ | ទំហំ ៥៥ ហិកតា | នេសាទពេញមួយឆ្នាំ |
| -នាទីព្រៃកោងកាង | ទំហំ ៩ ហិកតា | នេសាទពេញមួយឆ្នាំ |
| -ព្រែកចំនួន៣ | ទំហំ ២០ម៉ែត្រ x ៩០០ ម៉ែត្រ | នេសាទពេញមួយឆ្នាំ។ |

**គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្សជលផល**

សហគមន៍នេសាទចង្ហោន បានសម្រេចបង្កើតកន្លែងអភិរក្សជលផលមួយកន្លែងមានទំហំ១០ហិកតា ស្ថិតនៅក្នុងកន្លែងសហគមន៍នេសាទចង្ហោន។ កន្លែងអភិរក្សជលផលនេះ ត្រូវបានធ្វើរៀបចំ និងគ្រប់គ្រងដោយសហគមន៍នេសាទ។

**ឃ. ធនធានជលផល**

ប្រទេសកម្ពុជា ធនធានជលផលដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង និងសេដ្ឋកិច្ច ហើយធនធានជលផលនេះ ផ្តល់ជាអាហារ និងមុខរបរនៃការចិញ្ចឹមជីវិតរបស់ប្រជានេសាទប្រចាំថ្ងៃ ជាពិសេសអ្នកនេសាទវ័យចាស់។ តាមការបង្ហាញពីសហគមន៍នេសាទចង្ហោន បានឱ្យដឹងថា បច្ចុប្បន្នធនធាជលផលក្នុងសមុទ្រនៅទីនេះមានស្ថានភាពល្អប្រសើរ ដោយសារមានការគ្រប់គ្រងល្អ។

**ប្រភេទត្រីសមុទ្រ ៖** ត្រីក្តចិន ត្រីក្បក ត្រីក្អុក ត្រីស្តុង ត្រីក្រហម ត្រីផ្ទោង ត្រីឆ្លាម ត្រីបបែល ត្រីការ៉ាវ ត្រីប្រម៉ា ត្រីកាឡាងំ ត្រីកន្តាំង ត្រីកន្ទុយរឹង ត្រីតុកកែ ត្រីអណ្តាតឆ្កែ ត្រីម្រេច ត្រីបាឃើ ត្រីអង្រែ ត្រីទក់សមុទ្រ ត្រីប្លាធូ ត្រីអាំងកើយ ត្រីសេះ ត្រីសេក។

**ប្រភេទវារីសត្វសមុទ្រ ៖** បង្គា បង្កង បង្កងកន្ទប បង្កងប៉ាក ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ ក្តាមប្រង់ មឹកគ្រែងឈាម ងាវ ងាវភក់ ងាវហូល ងាវស អណ្តើក កន្ទាយ បាលង្កាស កញ្ច អន្ទង់ ខ្ចឹង ផ្សោតស ផ្សោតខ្មៅ ។ល។

**ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ៖** ដើមកោងកាង ក្រញឹប អម្ពូ អម្ពា ក្របាញញី ក្របាញឈ្មោល ប៉ុង ប្រាសាក់ ដើមបើស ឈើជ័រ ដើមក្លាយ អញ្ចរ ដើមឡេវអាវ ចាក ប្រង់ ដើមដូងទឹក ផ្កាថ្ម ស្មៅសមុទ្រ ។ល។

**៤. ការធ្វើនេសាទ**

**ក. អ្នកនេសាទ ៖**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១៨០នាក់ ស្រី៩២នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍៤៣នាក់ ស្រី១៣នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៥៧នាក់ ក្នុងមួយឆ្នាំ។

**ខ. ឧបករណ៍**នេសាទ ៖

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| **ប្រភេទ ឧបករណ៍** | **ឯកតា** | ចំនួន គ្រួសារ | ចំនួន ឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវនេសាទ |
|---|---|---|---|---|---|
| មងត្រី | ម៉ែត្រ | ២៣ | ១៦ដៃ/គ្រួសារ(១ដៃ=៦០ម) | ក្រឡា៣,៥ស.មx១០០០ម | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ១៥ | ១៣ដៃ/គ្រួសារ(១ដៃ=៦០ម) | ក្រឡា៣,៥ស.មx៨០០ម | ឧសភាដល់កញ្ញា |
| លបក្តាម | លប | ៩ | ៥០០លប/គ្រួសារ | ០,៣.មx០,៥ម | ពេញមួយឆ្នាំ |
| លបត្រី | លប | ៥ | ១៥លប/គ្រួសារ | ០,៨មx១,២ម | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ១០ | ៣០០-១០០០ផ្លែ/គ្រួសារ | ផ្លែលេខ១-៤ | ពេញមួយឆ្នាំ |
| សន្ទូចត្រីស្តង់ | ផ្លែ | ៥ | ៥ផ្លែ/គ្រួសារ | ផ្លែលេខ៤-៧ | ពេញមួយឆ្នាំ |

| | | | | | |
|---|---|---|---|---|---|
| សន្ទូចត្រីទឹកកៃ | ផ្លែ | ៣ | ៥ផ្លែ/គ្រួសារ | ផ្លែលេខ៤-៧ | ពេញមួយឆ្នាំ |
| សន្ទូចរនងមឹក | ផ្លែ | ១០ | ៣០ផ្លែ/គ្រួសារ | ផ្លែលេខ១-៤ | ពេញមួយឆ្នាំ |
| ឈិបរុញដៃ | គ្រឿង | ១៥ | ១គ្រឿង/គ្រួសារ | ៦ ម x ៦ម | ពេញមួយឆ្នាំ |
| រាវបង្គា | នាក់ | ២០ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |
| រាវក្រែងឈាម | នាក់ | ១៧ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |
| ចាក់ខ្យងចាក់ប្រែង | នាក់ | ១៥ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |
| ចាក់បង្កា | នាក់ | ៨ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |
| លូកក្ដាមថ្ម | នាក់ | ១៥ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |
| ចាប់ក្ដាមជំរ | នាក់ | ១០ | ១នាក់/គ្រួសារ | - | ពេញមួយឆ្នាំ |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៩៨គ្រឿង | ៧០០-១០០០គីឡូក្រាម | ៦-១៣ សេះ |

**ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖**

| **ឧបករណ៍នេសាទ** | **ឯកតា** | **ចំនួនគ្រួសារ** | **ចំនួនឧបករណ៍នេសាទ** | **ទំហំ/ប្រវែង** | **រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....)** |
|---|---|---|---|---|---|
| មងត្រីក្បក | ម៉ែត្រ | ៤ | ១៦ដៃ/គ្រួសារ(១ដៃ=៦០ម) | ក្រឡា៣,៥ស.មx១០០០ម | ពេញមួយឆ្នាំ |
| មងត្រីផ្ទោង | ម៉ែត្រ | ៣ | ១៣ដៃ/គ្រួសារ(១ដៃ=៦០ម) | ក្រឡា២,៥ស.មx៨០០ម | ពេញមួយឆ្នាំ |
| មងបង្គា | ម៉ែត្រ | ៨ | ១៣ដៃ/គ្រួសារ(១ដៃ=៦០ម) | ក្រឡា៣,៥ស.មx ៨០០ម | ពេញមួយឆ្នាំ |
| មងត្រីកាម៉ុង | ម៉ែត្រ | ៥ | ២០ដៃ/គ្រួសារ(១ដៃ=៦០ម) | ក្រឡា៣,៥ស.មx១២០០ម | ពេញមួយឆ្នាំ |
| មងត្រីកន្ដាំង | ម៉ែត្រ | ២ | ១៦ដៃ/គ្រួសារ(១ដៃ=៦០ម) | ក្រឡា៤ស.មx ១០០០ម | ពេញមួយឆ្នាំ |
| លបក្ដាម | លប | ១១ | ៥០០លប/គ្រួសារ | ០,៣.មx០,៥ម | ពេញមួយឆ្នាំ |
| សន្ទូចរនងមឹក | ផ្លែ | ៣ | ៣០ផ្លែ/គ្រួសារ | ផ្លែលេខ១-៤ | ពេញមួយឆ្នាំ |
| ឈិបរុញដៃ | គ្រឿង | ៥ | ១គ្រឿង/គ្រួសារ | ៦ ម x ៦ម | ពេញមួយឆ្នាំ |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១៥ គ្រឿង | ៧០០-១០០០គីឡូក្រាម | ៦-១៣ សេះ |

**ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖**

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន នាក់ | ចំនួន ឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងក្តាម | ម៉ែត្រ | ២០ | ១៣ដៃ(១ដៃ=៦០ម) | ៨០០ម៉ែត្រ/គ្រួសារ | **វិច្ឆិកាដល់**សីហា |
| លបក្តាម | លប | ១៥ | ៥០០លប/គ្រួសារ | ០,៣.មx០,៥ម | **តុលាដល់**មេសា |
| លបត្រី | ម៉ែត្រ | ៥ | ២៥០លប/គ្រួសារ | ០,៨មx១,២ម | **ពេញរដូវនេសាទ** |
| លូកក្តាមថ្ម ក្តាមជ័រ | នាក់ | ១៥ | ១នាក់/គ្រួសារ | - | **វិច្ឆិកាដល់**សីហា |
| ឈិបរុញដៃ | គ្រឿង | ១៨ | ១-២គ្រឿង/គ្រួសារ | ៦ ម x ៦ម | **ពេញរដូវនេសាទ** |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៨ គ្រឿង | ៤០០-១០០០ គីឡូក្រាម | ៦-១៣ សេះ |
| ប្រើម៉ូតូ | ១០ គ្រឿង | | - |

**គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ្រួសារអ្នកនេសាទ) | | |
|---|---|---|---|
| | **រដូវប្រាំង** | **រដូវវស្សា** | **សរុបប្រចាំឆ្នាំ** |
| ត្រីគ្រប់ប្រភេទ | ៣៧៨ គីឡូក្រាម | ៤៤៥ គីឡូក្រាម | ៨២៣ គីឡូក្រាម |
| បង្គា | ៤៤៣ គីឡូក្រាម | ២៩៨ គីឡូក្រាម | ៤៤១ គីឡូក្រាម |
| ក្តាម | ៣២៣ គីឡូក្រាម | ២៦៧ គីឡូក្រាម | ៥៩៩ គីឡូក្រាម |
| មឹក ខ្យង និងគ្រែងឈាម | ៥៩៨ គីឡូក្រាម | ៤៧៩ គីឡូក្រាម | ១០៧៧ គីឡូក្រាម |
| សរុប | ១៧៤២ គីឡូក្រាម | ១៤៨៩ គីឡូក្រាម | ២៩៤០ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក. ទស្សនៈវិស័យ ៖

សហគមន៍នេសាទចង្ហោន មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលសមុទ្រ ប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

### ខ. គោលបំណង ៖

- ចូលរួមគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រ ដែលជាកន្លែងសហគមន៍នេសាទ នាទីព្រៃកោងកាង វាលភក់ និងកន្លែងនាទីទឹកជោរនាច
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

### គ. ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ

### ផ្នែកទី១. ការអភិបាលកិច្ចនិងការគ្រប់គ្រង

#### គ១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ នៅចំណុចចុងផ្លូវបេតុង ជាប់ផ្លូវទូក ចំណុចនិយាមកា X. 388963 Y. 1169442 ស្ថិតក្នុងភូមិចង្ហោន សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាព និងអ្នកពាក់ព័ន្ធ | -មានការចូលរួម<br>-មានការគាំទ្រ | ៥០០ | សហគមន៍នេសាទ ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០២៦ | សីហា ២០២៨ |
| សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៨មx១៣ម ធ្វើពីបេតុង រួមផ្សំគ្រឿងឈើ ប្រក់ក្បឿង បន្ទប់មួយជ្រុង រៀបជញ្ជាំងឥដ្ឋ និងមានបង្គន់អនាម័យ | -ស.ន មានកន្លែងធ្វើការ<br>-មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រងកន្លែងសហគមន៍នេសាទ | ២៥ ០០០ | | ២០២៦ | សីហា ២០២៨ |
| រៀបចំតបណ្ដាញអគ្គីសនី | មានថាមពលអគ្គីសនីធ្វើការ | ១ ៥០០ | | ២០២៦ | សីហា ២០២៨ |
| តនិងរៀបចំប្រព័ន្ធទឹកស្អាត ស៊ីទែនជ័រ ២ ចំណុះ ៥ ០០០លីត្រ | មានទឹកស្អាតប្រើប្រាស់ | ១ ២០០ | | | |
| ទិញសម្ភារសហគមន៍នេសាទ (តុ ទូ ក្ដារខៀន កៅអី កំព្យូទ័រ ព្រីនធើ) | មានសម្ភារសម្រាប់ធ្វើការ | ១ ៥៥០ | | | |

(ម = ម៉ែត្រ)

## គ២- ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងាររបស់គណៈកម្មការសហគមន៍នេសាទ

ផែនការប្រជុំនិងទិញសម្ភារអនុវត្តន៍ការងារគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

<table>
<tr><th>សកម្មភាព</th><th>លទ្ធផលរំពឹងទុក</th><th>ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)</th><th>អ្នកចូលរួម</th><th>ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម</th><th>ថ្ងៃ ខែ ឆ្នាំ បញ្ចប់</th></tr>
<tr><td>ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្ដាហ៍ទី១នៃខែ រៀងរាល់ខែឬត្រីមាស</td><td>-របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តន៍បន្ត<br>-លើកឡើងពីបញ្ហាប្រឈម និងតម្រូវការ</td><td>៦៦០</td><td>-គណៈកម្មការ<br>-ក្រុមល្បាត</td><td>កញ្ញា ២០២៥</td><td>សីហា ២០២៨</td></tr>
<tr><td>ចូលរួមប្រជុំជាមួយអាជ្ញាធរសង្កាត់ ក្រុង ឬអង្គភាពពាក់ព័ន្ធ</td><td rowspan="2">-ទទួលព័ត៌មាន និងផ្ដល់របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-បញ្ចូលផែនការណ៍ជាមួយផែនការអភិវឌ្ឍន៍សង្កាត់<br>-មានដំណោះស្រាយ</td><td rowspan="2">៦៥០</td><td>-អាជ្ញាធរឃុំ<br>-គណៈកម្មការ</td><td rowspan="2">កញ្ញា ២០២៥</td><td rowspan="2">សីហា ២០២៨</td></tr>
<tr><td>ចូលរួមប្រជុំជាមួយបណ្ដាញសហគមន៍នេសាទថ្នាក់ស្រុក ឬថ្នាក់ខេត្ត</td><td>-អាជ្ញាធរស្រុក/ខេត្ត<br>-បណ្ដាញស.ន</td></tr>
<tr><td>ចុះប្រជុំដើម្បីជម្រុញការចុះបញ្ជីទូកម៉ាស៊ីន ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធ ជាប្រចាំ</td><td>- បានចុះបញ្ជីទូកម៉ាស៊ីនគ្រប់ចំនួន<br>- ទូកម៉ាស៊ីនធ្វើនេសាទបានដាក់ប្រព័ន្ធតាមដាន<br>-បទល្មើសនេសាទថយចុះ</td><td>៦០០</td><td>គណៈកម្មការ<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល<br>ស្ថាប័នពាក់ព័ន្ធ</td><td>កញ្ញា ២០២៥</td><td>សីហា ២០២៨</td></tr>
<tr><td>ចុះអនុវត្តន៍សកម្មភាពការប្រមូលព័ត៌មាន ការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី</td><td>-មានព័ត៌មានច្បាស់លាស់<br>-រៀបចំផែនការបានត្រឹមត្រូវ<br>-ការគ្រប់គ្រងស.នបានល្អ</td><td>៩០០</td><td>-គណៈកម្មការ<br>-សមាជិកស.ន</td><td>កញ្ញា ២០២៥</td><td>សីហា ២០២៨</td></tr>
<tr><td>-សម្ភារការិយាល័យ<br>- LCD with Screen<br>-ទិញក្រដាស់ ប៊ិច<br>-ព្រីនឯកសារ កូពី<br>-ការទំនាក់ទំនង</td><td>មានសម្ភារការិយាល័យសម្រាប់ប្រើប្រាស់</td><td>២ ០០០</td><td>គណៈកម្មការ</td><td>កញ្ញា ២០២៥</td><td>សីហា ២០២៨</td></tr>
</table>

(ស.ន = សហគមន៍នេសាទ)

**គ៣- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល**

ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ មានដូចខាងក្រោម ៖

| **សកម្មភាព** | **លទ្ធផលរំពឹងទុក** | **ប៉ាន់ប្រមាណតម្លៃ (ដុល្លារ)** | **អ្នកចូលរួម** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម** | **ថ្ងៃ ខែ ឆ្នាំ បញ្ចប់** |
|---|---|---|---|---|---|
| ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយស្តីពី ៖<br>-ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីសហគមន៍កសិកម្ម ឯកសារគតិយុត្តិនានាពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងស.ន និងផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ<br>-ការរៀបចំនិងទុកដាក់សម្រាម<br>-បទពិសោធន៍នានាទទួលបាន | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់នានាដែលបានផ្សព្វផ្សាយ<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឱ្យជីវភាពធូរធារ | ២ ៥៨០ | គណៈកម្មការ, សមាជិកស.ន និងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូ | ឧសភា-ធ្នូ/ រៀងរាល់ឆ្នាំ | |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | | ១៦០ | | កញ្ញា ២០២៥ | សីហា ២០២៨ |
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានា | | ៤៥០ | | | |
| ផ្សព្វផ្សាយដល់សមាជិកសហគមន៍នេសាទ ដើម្បីចុះបញ្ជីទូកម៉ាស៊ីន | សមាជិកសហគមន៍នេសាទបានចុះបញ្ជីទូកម៉ាស៊ីនតាមច្បាប់ | ៤៥០ | | កញ្ញា ២០២៥ | សីហា ២០២៨ |
| ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល ៖<br>-កំណត់ហេតុ និងរបាយការណ៍<br>-គម្រោងស្នើសុំថវិកានិងការគ្រប់គ្រងថវិកាសហគមន៍នេសាទ | គណៈកម្មការ និងសមាជិកស.ន បានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ១ ៤០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | កញ្ញា ២០២៥ | សីហា ២០២៨ |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈកម្មការស.ន (២នាក់) | ៣៦០ | គណៈកម្មការស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន ដោយការកត់ត្រាទូកនេសាទ ឧបករណ៍នេសាទ និងផលចាប់ត្រី | គណៈកម្មការសហគមន៍នេសាទបានយល់ដឹង និងអាចអនុវត្តន៍បានក្នុងការងារជាក់ស្តែង | ៨០០ | គណៈកម្មការនិង សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | | |
| វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលនិងដោះស្រាយទំនាស់ | | ៤០០ | គណៈកម្មការ ជំនាញជលផល | | |

(ស.ន = សហគមន៍នេសាទ)

## គ.៤ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ គឺរៀបចំឡើងដោយគិតគូរនូវប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| កន្លែងនេសាទសហគមន៍ចង្ហោន (គណៈកម្មការ និងសមាជិកសហគមន៍នេសាទ) | ពេញរដូវនេសាទ | មងត្រីក្បក | ក្រឡា ៣,៥ស.មឡើង | ៨០០ម/គ្រួសារ | |
| | | មងត្រីឆ្តង | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្អក | ក្រឡា ៩ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីអណ្តាតឆ្កែ | ក្រឡា ៥,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីចាប | ក្រឡា ៦ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបបែល | ក្រឡា ១៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីព្រលួស | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីប្រខុប ឬត្រីកាម៉យ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាប៉ាស់ ឬត្រីដូរអង្គរ | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីក្បាន្ត | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីផ្ទោង | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកន្តាំង | ក្រឡា ៤ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងក្តាម | ក្រឡា ៨ ស.មឡើង | ៨០០ម/គ្រួសារ | |
| | | មងប៉ាកាំង ឬបង្កងកន្លប | ក្រឡា ៣ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីកាម៉ុង | ក្រឡា ៣,៥ ស.មឡើង | ៨០០ម/គ្រួសារ | |
| | | មងត្រីកន្ធយរឹង | ក្រឡា ៤,៨ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីការ៉ាវ | ក្រឡា ៧ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបេកា | ក្រឡា ៨ ស.មឡើង | ៣០០ម/គ្រួសារ | |
| | | មងត្រីសំប៉ាន | ក្រឡា ១០ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងត្រីគូន | ក្រឡា ២,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា១ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងបង្គា៣ជាន់ | ក្រឡា ៣,៥ ស.មឡើង | ៥០០ម/គ្រួសារ | |
| | | មងហ៊ុម | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | លបមឹក | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបក្តាម | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបបង្គា | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបខ្យង | ក្រឡា ៦ ស.មឡើង | ៨០លប/គ្រួសារ | |
| | | លបត្រី | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបត្រីតុកកែ | ក្រឡា ៦ ស.មឡើង | ២០លប/គ្រួសារ | |
| | | លបប្រើសច្រើន/កន្ទុយកណ្តុរ | ក្រឡា ៣ ស.មឡើង | ២០លប/គ្រួសារ | |
| | | អួនត្រីស | ក្រឡា ២,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនត្រីកាឡេងតេង | ក្រឡា ១,៥ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនហ៊ុមកៀនច្រាំង | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | អួនខ្វរ ឬមងខ្វរ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| | | អួនកេវ ឬមងកេវ | ក្រឡា ៣ ស.មឡើង | ១០០ម/គ្រួសារ | |
| | | សន្ទូចរនងត្រី | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងបបែល | មិនកំណត់ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចរនងមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | រនងធ្នាក់មឹក | - | ៨០០គ្រាប់/គ្រួសារ | |
| | | សន្ទូចត្រីបេកា | - | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចមឹក | ផ្លែលេខ១-៤ | ៥០០ផ្លែ/គ្រួសារ | |
| | | សន្ទូចដៃ | មិនកំណត់ | មិនកំណត់ | |
| | | សន្ទូចបបក់ | មិនកំណត់ | មិនកំណត់ | |
| | | ឈិបរុញដោយដៃ | ក្រឡា ១,៥ ស.មឡើង | មិនកំណត់ | |
| | | រាវគ្រែងឈាម | មិនកំណត់ | មិនកំណត់ | |
| | | រាវងាវភក់ | មិនកំណត់ | មិនកំណត់ | |
| | | លូកក្ដាមថ្ម ជ័រ | មិនកំណត់ | មិនកំណត់ | |
| | | សំណាញ់ | ក្រឡា ១,៥ ស.មឡើង | មិនកំណត់ | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

## គ៩-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ៖<br>-តាមមេក្រូ ២៤ដង/ឆ្នាំ<br>-បិទឯកសារ ១ដង/ឆ្នាំ<br>-ចែកឯកសារ<br>-ប្រជុំផ្សព្វផ្សាយ ១ដង/ឆ្នាំ សីហា/រៀងរាល់ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទនិងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ | ១ ៥៦០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រជុំប្រចាំខែ ឬឆមាស (កក្កដានិងធ្នូ/រៀងរាល់ឆ្នាំ) | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តន៍ការងារ | ៣៦០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ | | |
| អនុវត្តន៍ផែនការ៖ (រៀបចំកំលាំងចុះល្បាតដល់ទីកន្លែង ដោយទំនាក់ទំនង និងឬ សហការជាមួយ អាជ្ញាធរមូលដ្ឋាន និងឬ អង្គភាពពាក់ព័ន្ធ) (៤ដង/ខែ = ១៤៤/ដង) | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកសហគមន៍នេសាទធូរធារ | ១០ ៣៦៨ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |

| | | | | | |
|---|---|---|---|---|---|
| មធ្យោបាយនិងសម្ភារ<br>-សាំង និងប្រេងបាត<br>-អាវ ស្បែកជើង មួក អាវភ្លៀង អាវពោង ពិល អាយកូម ម៉ាស៊ីនថត កែវយឺត កាតទូរស័ព្ទ | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាព | ៣ ៣៤៦ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ទិញទូកស្នាច់និងម៉ាស៊ីនថ្មី ចំនួន២គ្រឿង | មានមធ្យោបាយចុះល្បាត | ៤ ០០០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | | |
| គៀងគរថវិកាក្នុងការឧបបត្ថម្ភ ឬបដិភាគដល់ប្រជានេសាទដែលឈប់ឬផ្លាស់ប្តូរការប្រើឧបករណ៍នេសាទខុសច្បាប់ | កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ | ៥ ០០០ | សហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការដៃគូ | កញ្ញា ២០២៥ | សីហា ២០២៨ |

**គ.៦ ផែនការកែលម្អ**កន្លែងសហគមន៍នេសាទ

ផែនការកែលម្អដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| **ដែននេសាទ** | **ទំហំ** (ហិកតា) | **ទំហំដែលត្រូវកែលម្អ** | **សកម្មភាព** | **ប៉ាន់ប្រមាណតម្លៃ(ដុល្លារ)** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម** | **ថ្ងៃ ខែ ឆ្នាំ បញ្ចប់** |
|---|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ចង្ហោន | ១ ៣៣៨ | ១ ៣៣៨ ហិកតា | ប្រជុំផ្សព្វផ្សាយដល់អង្គភាព អាជ្ញាធរ ស្ថាប័ន និងអ្នកពាក់ព័ន្ធ | ១០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | សាងសង់ផ្ទាំងប៉ាណូផ្សព្វផ្សាយ ២ផ្ទាំង ២,៥០ ម x ២ម គ្រឿងដែក(ដែកមូល) | ១ ២០០ | | |
| | | | ស្លាកសញ្ញាផ្សព្វផ្សាយ១០ផ្ទាំង១,២មx១ម គ្រឿងដែក(ដែកមូល) | ២ ០០០ | | |
| | | | កំណត់ទីតាំងតាមនិយាមកានិងបោះបង្គោលព្រំប្រទល់សហគមន៍នេសាទលើគោក ៧ បង្គោល ធ្វើពីបេតុង សរសៃដែក | ១ ០៥០ | | |
| | | | បោះបង្គោលព្រំប្រទល់សហគមន៍នេសាទក្នុងទឹក ៥ បង្គោល ធ្វើពីបេតុង ទំហំ០,៣មx៨ម | ៦ ០០០ | | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

## គ.៧ ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផលរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំកន្លែងអភិរក្សជលផល ត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះផែននេសាទ | ទំហំត្រូវអភិរក្ស (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| កន្លែងអភិរក្សជលផល ១០ ហិកតា<br>387603-1169056<br>387761-1169362<br>388006-1169198<br>387856-1168899<br> | ១០ | -ស្មៅសមុទ្រ<br>-ខ្យងជើង១<br>-គ្រែងឈាម<br>-ក្តាមសេះ<br>-ផ្កាថ្ម<br>-ជីវចម្រុះ | ផ្សព្វផ្សាយពីកន្លែងអភិរក្សជលផលដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ | ៤៥០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | ចុះរកទីតាំងជាក់ស្តែងតាមនិយាមកា | ៣០០ | | |
| | | | បោះបង្គោលព្រំកន្លែងអភិរក្សជលផលធ្វើពីស៊ីម៉ង់ គ្រឿងដែក (សាជី) ចំនួន៤បង្គោល | ២ ៨០០ | | |
| | | | ពង្រាយប្រអប់សិប្បនិម្មិតធ្វើពីបេតុង ចំនួន១០០ ប្រអប់ | ១០ ០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣០០ | | |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សភ្ជាប់ជាមួយបង្គោលធ្វើពីគ្រឿងឈើ ប្រក់ហ្វីប្រូស៊ីម៉ង់ | ៧០០ | | |
| | | -ត្រីផ្សោត<br>-ជីវចម្រុះ | ចុះសិក្សាប្រមូលព័ត៌មាន | ៥០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | ប្រជុំផ្សព្វផ្សាយពីកន្លែងសាងសង់ជម្រកសិប្បនិម្មិត | ៥០០ | | |
| | | | ពង្រាយជម្រកត្រីសិប្បនិម្មិតធ្វើពីបេតុង ចំនួន៥០ កន្លែង | ១៥ ០០០ | | |
| | ១០០ម x ១០០ម | | បង្កើតកន្លែងស្មៅសមុទ្រ ដើម្បីបង្កើនផលស្តុកធម្មជាតិពង្រាយឧបករណ៍ស៊ីឡាំងស្មៅសមុទ្រសិប្បនិម្មិតជារបបគំហើញថ្មីមកពីប្រទេសជប៉ុន | ១៤ ០០០ | | |

## គ.៨ ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះរបស់សហគមន៍នេសាទ

ផែនការកំណត់និងរៀបចំស្ថានីយ៍ភ្ញាស់កូនក្តាមសេះ ត្រូវរៀបចំឡើង ដើម្បីបង្កើនផលស្តុកធម្មជាតិនៃធនធានជលផល ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះផែននេសាទ | ទំហំ (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| កន្លែងនេសាទសហគមន៍ចង្ហោន | ១ ស៊ុមក្តាមសេះ ៥០មx៥០ម | -ស្មៅសមុទ្រ<br>-ក្តាមសេះ<br>-ជីវចម្រុះ | ផ្សព្វផ្សាយដល់ប្រជានេសាទឱ្យបានទូលំទូលាយដើម្បីប្រមូលក្តាមសេះពង | ៣៦០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | សាងសង់ស្ថានីយ៍១កន្លែង ៣មx៤ម និងស្ពានដើរជុំវិញស្ថានីយ៍ ធ្វើពីគ្រឿងឈើ | ១២ ០០០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| 388113-1169330<br>388006-1169399<br>388051-1169469<br>388156-1169395 | | | និងសម្ភារជាង | | | |
| | | | បោះបង្គោលព្រំកន្លែងការពារក្តាម សេះ និងព័ទ្ធស្បៃមុង | ៨០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | ពង្រាយប្រអប់សិប្បនិម្មិតធ្វើពីបេតុង ចំនួន៥០ ប្រអប់ | ៥ ០០០ | | |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ២០០ | | |
| | | | ព្រលែងកូនក្តាម និងមេក្តាមពង | ៥០០ | | |
| | | | ថែទាំ និងប្រមូលផល | ១០០ | | |
| | | | ឧបករណ៍សម្ភារគាំទ្រសកម្មភាពភ្ញាស់ក្តាម | ៥០០ | | |

(ម = ម៉ែត្រ)

### គ.៩ ផែនការគ្រប់គ្រងព្រៃកោងកាង

ផែនការគ្រប់គ្រងកោងកាង ត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|---|
| ព្រៃកោងកាងដែលមានស្រាប់ក្នុងកន្លែងសហគមន៍នេសាទ | ៩ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យទូលំទូលាយដល់ប្រជាពលរដ្ឋ | ប្រជុំ | ៣០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | ដាក់ស្លាកសញ្ញាស្តីពីដែនទីព្រៃកោងកាង ២ ស្លាក ២,៥ម x ១,៥ម ធ្វើពីគ្រឿង ដែកចាក់បេតុង | | ៨០០ | | |
| | | | ថែរក្សា ការពារ | | | | |
| វាលភក់ស្ថិតក្នុងកន្លែងនេសាទសហគមន៍ ២០,៨ហិកតា | ទំហំត្រូវដាំ ៨,៨ | ព្រៃកោងកាង | ផ្សព្វផ្សាយពីកន្លែងព្រៃកោងកាងឱ្យបានទូលំទូលាយ | ប្រជុំ | ៣០០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | | | | ចែកឯកសារ | ១០០ | | |
| | | | រកចំណុចទីតាំងដាក់ស្តែងតាមនិយាមកា | | ២០០ | | |
| | | | ដាក់ស្លាកសញ្ញាដែនទីព្រៃកោងកាងធ្វើពីគ្រឿងដែកចាក់បេតុង២ស្លាក២,៥មx១,៥ម | | ៨០០ | | |
| | | | រៀបចំថ្នាលបណ្តុះកូនកោងកាង បង្គោលឈើ និងស្បៃ ១០ម x ២០ម | | ១ ០០០ | | |
| | | | បណ្តុះកូនកោងកាងចំនួន៦១ ៦០០ដើម (១ហិកតាx៧០០០ដើម) | | ៦១ ៦០០ | | |
| | | | ដាំកូនកោងកាង ១៥នាក់x៨,៥ដុល្លារ/ថ្ងៃ | | ៣ ០០០ | | |
| | | | ថែទាំដើមកោងកាង រយៈពេល៣ខែដំបូង ៤នាក់ x ១០ដុល្លារ/ថ្ងៃ,២ថ្ងៃ/អាទិត្យ | | ១ ០០០ | | |
| | | | ពី៣ខែដល់៦ខែ ៤នាក់ x ១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/អាទិត្យ | | ១ ០០០ | | |
| | | | ពី៦ខែឡើង ៤នាក់x១០ដុល្លារ/ថ្ងៃ,១ថ្ងៃ/ខែ | | ១ ២០០ | | |

(ស.ម = សង្ទីម៉ែត្រ, ម = ម៉ែត្រ)

## ផ្នែកទី២. សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នេសាទ

### គ១០- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការបណ្តុះបណ្តាល | | | | | |
| ចិញ្ចឹមគ្រែងឈាម | -មានចំណេះដឹងក្នុងការចិញ្ចឹម<br>-យកទៅអនុវត្តជាក់ស្តែងបាន<br>- សមាជិកនិងគណៈកម្មការស.ន ទទួលបានចំណេះដឹងលើគុណភាពទឹក តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជាតិពុលក្នុងទឹក ការពិនិត្យគុណភាពទឹក ការតាមដាន និងរាយការណ៍<br>-ការអនុវត្តសាកល្បងលើការចិញ្ចឹមដោយមិនប្រើចំណី។ | ៩០០ | គណៈកម្មការនិងសមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ចិញ្ចឹមក្តាមថ្ម | | ៩០០ | | | |
| ចិញ្ចឹមងាវភក់ | | ៩០០ | | | |
| ចិញ្ចឹមខ្យងចំពុះទា | | ៩០០ | | | |
| ចិញ្ចឹម(ត្រីឆ្តង់ ត្រីទឹកកៃ ត្រីផ្ទក់សមុទ្រ ត្រីអាំងកីយ កង្កែប និងអន្ទង់) | -មានចំណេះដឹង<br>-មានសុវត្ថិភាពចំណីអាហារ<br>-មានជម្រើសមុខរបរ<br>-បង្កើនប្រាក់ចំណូល | ១ ៨០០ | គណៈកម្មការនិងសមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| កែច្នៃផលនេសាទ | | ៩០០ | | | |
| បច្ចេកទេសកំណត់អាទិភាពជម្រើសមុខរបរ | -មានចំណេះដឹង<br>-មានមុខរបរខ្នាតតូច ឬសិប្បកម្ម<br>-បង្កើនប្រាក់ចំណូល | ៩០០ | គណៈកម្មការនិងសមាជិកស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាទេសចរណ៍ជលផល | -ក្រុមចុងភៅ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមធ្វើរយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលកសិកម្ម<br>-ក្រុមរោងលម្ហែ (កញ្ចះ) | ១ ០០០ | គណៈកម្មការនិងសមាជិស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| បណ្តុះបណ្តាលពីសហគ្រិនភាពដល់គណៈកម្មការ និងសមាជិកស.ន | គណៈកម្មការនិងស្ត្រីមានមានការយល់ដឹងពីសហគ្រិនភាពប្រមាណ ២០ភាគរយ និងអាចអនុវត្តន៍ក្នុងសកម្មភាពសេដ្ឋកិច្ច និងអាជីវកម្ម | ៥០០ | គណៈកម្មការសហគ្រិនខ្មែរ | កញ្ញា ២០២៥ | សីហា ២០២៨ |
| ២.ទស្សនៈកិច្ចសិក្សា | ទទួលបានបទពិសោធន៍បន្ថែម | ២ ៥០០ | គណៈកម្មការនិងសមាជិស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ៣.ផែនការបង្កើតក្រុមមុខរបរ | | | | | |
| ក្រុមចិញ្ចឹមគ្រែងឈាម | -មានក្រុមចិញ្ចឹមគ្រែងឈាម | ៩០០ | គណៈកម្មការនិង | កញ្ញា | សីហា |

| | | | | | |
|---|---|---|---|---|---|
| ក្រុមចិញ្ចឹមក្តាមថ្ម<br>ក្រុមចិញ្ចឹមងាវភក់<br>ក្រុមចិញ្ចឹមខ្យងចំពុះទា | ក្តាមថ្ម និងងាវភក់<br>-មានគ្រែងឈាម តាមថ្ម និងងាវភក់ផ្គត់ផ្គង់ទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | | សមាជិស.ន | ២០២៥ | ២០២៨ |
| ក្រុមចិញ្ចឹមត្រីឆ្លង់ ទឹកកែ ផ្ទក់សមុទ្រ អាំងកីយ កង្កែប និងអន្ទង់ | -មានក្រុមចិ.ត្រីឆ្លង់ ទឹកកែ ផ្ទក់សមុទ្រ អាំងកីយ កង្កែប អន្ទង់<br>-មានបន្លែផ្គត់ផ្គង់ដល់កន្លែងកំសាន្តនិងទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៨០០ | គណៈកម្មការនិង សមាជិស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |
| ក្រុមកែច្នៃផលនេសាទ ដោយផ្តោតលើ ៖<br>-ក្រុមស្ត្រី<br>-ជនងាយរងគ្រោះក្នុងស.ន | -មានក្រុមកែច្នៃផលនេសាទ<br>-មានផលិតផលជលផលផ្គត់ផ្គង់ដល់កន្លែងកំសាន្តនិងទីផ្សារ<br>-មានមុខរបរនិងប្រាក់ចំណូល | ៥០០ | គណៈកម្មការនិង សមាជិស.ន | កញ្ញា ២០២៥ | សីហា ២០២៨ |

(ស.ន = សហគមន៍នេសាទ)

**គ១១-ផែនការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ**

ផែនការសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទ កូនត្រីពូជ | បរិមាណ កូនត្រីពូជ | ប៉ាន់ស្មាន តម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ក្រុមចិញ្ចឹមត្រីឆ្លង់ តាមបែរ២០បែរ | ២០បែរx៤មx៣មx២ម | ត្រីឆ្លុង | ២៤០០០ | ១៦ ៦៦០ | កញ្ញា ២០២៥ | សីហា ២០២៨ |
| | សាងសង់បែរ | | - | | | |
| ក្រុមចិញ្ចឹមត្រីទឹកកែ តាមបែរ១០បែរ | ១០បែរx៤មx៣មx២ម | ត្រីទឹកកែ | ១២ ០០០ | ៨ ៣៣០ | | |
| | សាងសង់បែរ | | - | | | |
| ក្រុមចិញ្ចឹមត្រីផ្ទក់សមុទ្រ ១០បែរ | ១០បែរx៤មx៣មx២ម | ត្រីផ្ទក់សមុទ្រ | ១២ ០០០ | ៨ ៣៣០ | កញ្ញា ២០២៥ | សីហា ២០២៨ |
